# របាយការណ៍គ្រប់គ្រងប្រចាំឆ្នាំ ២០២៣ និងត្រីមាសទី១ ឆ្នាំ២០២៤

# ANNUAL REPORT FOR YEAR 2023 AND FIRST QUARTER OF 2024

# មាតិកា


អំពី ម.ជ.ម.

ការគ្រប់គ្រងសំណុំរឿង

រចនាសម្ព័ន្ធស្ថាប័ន

សកម្មភាពរបស់ ម.ជ.ម.

គោលដៅរបស់ ម.ជ.ម.

# ១. អំពី ម.ជ.ម.

ម.ជ.ម. ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦។

អនុលោមទៅតាមច្បាប់នេះ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យ លេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងអនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១២៤ អនក្រ.បក។



# សាររបស់
# ប្រធាន ម.ជ.ម.

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ភាគីពាក់ព័ន្ធទាំងអស់ដែលបានចូលរួមចំណែកក្នុងការបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) រួមមានថ្នាក់ដឹកនាំនៃក្រសួងពាណិជ្ជកម្ម សហគមន៍អ្នកធុរកិច្ច សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលបានឧបត្ថមគាំទ្រដល់វគ្គបណ្តុះបណ្តាលដំបូងបង្អស់ អ្នកបណ្តុះបណ្តាលដែលពោរពេញដោយបទពិសោធន៍ជាច្រើនរូបមកពីវិទ្យាស្ថានមជ្ឈត្តការសិង្ហបុរី (SIArb) និងមជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិសិង្ហបុរី (SIAC) ក្រុមប្រឹក្សាប្រតិបត្តិ និងក្រុមការងារនៃអគ្គលេខាធិការដ្ឋានរបស់ម.ជ.ម. ទាំងអតីត និងបច្ចុប្បន្ន ក៏ដូចជាមជ្ឈត្តករទាំងអស់។ បើគ្មានការគាំទ្រ ការលើកទឹកចិត្ត និងការខិតខំប្រឹងប្រែងឥតឈប់ឈររបស់ភាគីពាក់ព័ន្ធទាំងអស់ទេ ម.ជ.ម. ក៏មិនអាចមានវត្តមាន និងឈានមកដល់បច្ចុប្បន្ននេះដែរ។

---

ម.ជ.ម. បានកើតចេញពីបំណងដែលចង់ពង្រីកវិសាលភាពនៃការប្រើប្រាស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា និងដើម្បីដោះស្រាយវិវាទពាណិជ្ជកម្មក្នុងស្រុក និងអន្តរជាតិដែលកំពុងកើនឡើងគួរឱ្យកត់សម្គាល់ស្របតាមកំណើនសេដ្ឋកិច្ចនៅកម្ពុជា។ ការវិនិយោគបរទេសដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកដល់កំណើនសេដ្ឋកិច្ច ក៏ដូចជាកំណើននៃប្រតិបត្តិការពាណិជ្ជកម្មឆ្លងព្រំដែនផងដែរ។ អ្វីដែលសហគមន៍អ្នកធុរកិច្ចត្រូវការ គឺសមត្ថភាពដោះស្រាយវិវាទដែលកើតចេញពីប្រតិបត្តិការពាណិជ្ជកម្មទាំងនោះ ប្រកបដោយប្រសិទ្ធភាពតាមរយៈយន្តការដោះស្រាយវិវាទមួយដែលមានលក្ខណៈអព្យាក្រឹត្យ។ យន្តការមួយដែលអាចផ្តល់ឱ្យគូភាគីនូវស្វ័យភាពក្នុងការជ្រើសរើសមធ្យោបាយដោះស្រាយវិវាទ សេរីភាពក្នុងការជ្រើសរើសបុគ្គលត្រឹមត្រូវដែលមានជំនាញបច្ចេកទេសច្បាស់លាស់ក្នុងការធ្វើសេចក្តីសម្រេចលើវិវាទ និងសមត្ថភាពក្នុងការអនុម័តនីតិវិធីណាមួយដែលល្អបំផុតក្នុងការដោះស្រាយវិវាទរបស់គូភាគីដោយផ្អែកលើស្ថានភាពជាក់ស្តែងនៃប្រតិបត្តិការពាណិជ្ជកម្មនីមួយៗ។ សមត្ថភាពដោះស្រាយវិវាទប្រកបដោយទំនុកចិត្ត និងការអនុវត្តសេចក្តីសំម្រេចដែលមានវិសាលភាពជាសកល ក៏មានសារៈសំខាន់ចំពោះសហគមន៍អ្នកធុរកិច្ចផងដែរ។ ការប្រើប្រាស់យន្តការមជ្ឈត្តកម្ម គឺជាមធ្យោបាយឈានមុខ ដើម្បីឆ្លើយតបទៅនឹងតម្រូវការពាណិជ្ជកម្មនេះ។



> **"ម.ជ.ម. នឹងបន្តខិតខំប្រឹងប្រែងកសាងកេរ្តិ៍ឈ្មោះរបស់ខ្លួន ឱ្យក្លាយជាស្ថាប័នដ៏ទាក់ទាញមួយក្នុងការដោះស្រាយវិវាទ ដែលផ្តល់ជូននូវសេវាគ្រប់គ្រងសំណុំរឿងដ៏ល្អប្រសើរ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងមានភាពឆាប់រហ័ស។**

# រចនាសម្ព័ន្ធរបស់ ម.ជ.ម.

ម.ជ.ម. គ្រប់គ្រងដោយមហាសន្និបាត និងក្រុមប្រឹក្សាប្រតិបត្តិ។

## មហាសន្និបាត

មហាសន្និបាត ត្រូវបានចូលរួមដោយសមាជិកដែលជារូបវន្តបុគ្គល (សមាជិកមជ្ឈត្តករ) និងអ្នកតំណាងនៃសមាជិកជានីតិបុគ្គលនីមួយៗ របស់ ម.ជ.ម.។

## ក្រុមប្រឹក្សាប្រតិបត្តិ

សមាសភាពនៃក្រុមប្រឹក្សាប្រតិបត្តិគឺត្រូវបានបោះឆ្នោតជ្រើសតាំងក្នុងចំណោមសមាជិក ម.ជ.ម. ដោយមហាសន្និបាត។ ប្រធាននៃក្រុមប្រឹក្សាប្រតិបត្តិ គឺជាប្រធាននៃ ម.ជ.ម.។ ក្រុមប្រឹក្សាប្រតិបត្តិគឺត្រូវបានបោះឆ្នោតជ្រើសតាំងរៀងរាល់ ៣ឆ្នាំម្តង។

## អគ្គលេខាធិការដ្ឋាន

អគ្គលេខាធិការដ្ឋានអនុវត្តតួនាទីដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង រួមមានការគ្រប់គ្រងសំណុំរឿងមជ្ឈត្តកម្ម កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ ទំនាក់ទំនងសាធារណៈ និងការផ្តល់ការបណ្តុះបណ្តាល។ ក្រុមការងារអគ្គលេខាធិការដ្ឋានរបស់ ម.ជ.ម. ប្រមូលផ្តុំដោយបុគ្គលដែលសកម្ម មានឆន្ទៈខ្ពស់ក្នុងការបំពេញការងារ ប្រកបដោយចំណេះដឹង និងជំនាញច្បាស់លាស់ ព្រមទាំងមានសមត្ថភាពក្នុងការប្រើប្រាស់ភាសាបរទេសយ៉ាងជំនាញផងដែរ។

## គណៈកម្មាធិការ

គណៈកម្មាធិការត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាប្រតិបត្តិ ដើម្បីអនុវត្តការងារ ឬគម្រោងជាក់លាក់ណាមួយ។ ម.ជ.ម. មានគណៈកម្មាធិការចំនួន ៤ (បួន) គឺគណៈកម្មាធិការតែងតាំង និងនីតិវិធី គណៈកម្មាធិការវិន័យ គណៈកម្មាធិការអប់រំ និងគណៈកម្មាធិការសមាជិកភាព។

## ក្រុមប្រឹក្សាពិគ្រោះយោបល់

ក្រុមប្រឹក្សាពិគ្រោះយបល់ជាអ្នកផ្តល់ព័ត៌មាន និងយោបល់ជំនាញដល់ ម.ជ.ម. លើបញ្ហាពាក់ព័ន្ធ ការអភិវឌ្ឍន៍ និងនិន្នាការផ្សេងៗ ទាក់ទងនឹងបទប្បញ្ញត្តិមជ្ឈត្តការអន្តរជាតិ ការអនុវត្តល្អៗ ច្បាប់ជាតិ និងអន្តរជាតិ និងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ការអនុវត្តធុរកិច្ច និងពាណិជ្ជកម្ម ការកសាង និងការគ្រប់គ្រងស្ថាប័ន ការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍វិជ្ជាជីវៈ។

# រចនាសម្ព័ន្ធរបស់ ម.ជ.ម.




ម.ជ.ម. សមាជិកភាពមានបួនប្រភេទគឺ៖

- សមាជិកមជ្ឈត្តករ
- សមាជិកជានីតិបុគ្គល
- សមាជិកគាំទ្រជារូបវន្តបុគ្គល
- សមាជិកគាំទ្រជានីតិបុគ្គល

ចាប់តាំងពីការបង្កើតក្នុងឆ្នាំ ២០១៣ មក ម.ជ.ម. បានអនុញ្ញាតឱ្យរូបវន្តបុគ្គលដែលបានចុះឈ្មោះសមាជិកជាមជ្ឈត្តករសរុបចំនួន ១១១ រូប បច្ចុប្បន្ននេះសមាជិកដែលសកម្មរបស់ ម.ជ.ម. មានចំនួន ៨០ រូប និងសមាជិកនីតិបុគ្គលមានចំនួន ១០ ស្ថាប័ន៖

១. សភាពាណិជ្ជកម្មអាមេរិកកាំងនៅកម្ពុជា
២. សភាពាណិជ្ជកម្មកម្ពុជា
៣. សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា
៤. សមាគមសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា
៥. សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា
៦. សភាពាណិជ្ជកម្មអន្តរជាតិកម្ពុជា
៧. សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា
៨. គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
៩. សមាគមក្រុមហ៊ុនកម្ពុជាស្វែងរករ៉ែ និងសិក្សាស្រាវជ្រាវ
១០. សភាពាណិជ្ជកម្មកូរ៉េនៅកម្ពុជា

# ក្រុមប្រឹក្សាប្រតិបត្តិអាណត្តិទី៤




# អគ្គលេខាធិការដ្ឋានរបស់ ម.ជ.ម.



# គណៈកម្មាធិការតែងតាំង និងទីតាំងធី




# គណៈកម្មាធិការអប់រំ និងបណ្តុះបណ្តាល



# គណៈកម្មាធិការសមាជិកភាព




# គណៈកម្មាធិការវិន័យ



# ២. ការគ្រប់គ្រងសំណុំរឿង

ចាប់តាំងពី ម.ជ.ម. បានចេញមជ្ឈត្តវិនិច្ឆ័យដំបូងរបស់ខ្លួនក្នុងឆ្នាំ ២០១៧ រហូតដល់ឆ្នាំ ២០២៣ ម.ជ.ម. បានចេញមជ្ឈត្តវិនិច្ឆ័យសរុបចំនួន ១៨ ។ មិនតែប៉ុណ្ណោះ មិនមានមជ្ឈត្តវិនិច្ឆ័យណាមួយរបស់ ម.ជ.ម. ត្រូវបានបដិសេដដោយតុលាការកម្ពុជា ឬតុលាការបរទេសនោះទេ។ លើសពីនេះទៅទៀត មជ្ឈត្តវិនិច្ឆ័យមួយរបស់ ម.ជ.ម. ត្រូវបានទទួលស្គាល់ និងអនុវត្តដោយតុលាការជាន់ខ្ពស់របស់ប្រទេសសិង្ហបុរីផងដែរ។

## ស្ថិតិមជ្ឈត្តវិនិច្ឆ័យរបស់ ម.ជ.ម.



# ស្ថិតិសំណុំរឿង




# ចំនួនសំណុំរឿងនៃឆ្នាំនីមួយៗ



# វិស័យនៃវិវាទ




# ភាគីនៃវិវាទ



# វគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការ និងវគ្គបណ្តុះបណ្តាលផ្សេងៗ

អនុក្រឹត្យ១២៤ បានតម្រូវឱ្យ ម.ជ.ម. ផ្តល់នូវសេវាកម្ម ក៏ដូចជាវគ្គបណ្តុះបណ្តាលស្តីអំពីយន្តការ ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីធានានូវស្តង់ដារគុណភាព នៃដំណើរការមជ្ឈត្តការក្នុងព្រះរាជាណាចក្រកម្ពុជា។

---

## ចំនួនអ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាល

ខែមីនា ឆ្នាំ 2023 - ខែមីនា ឆ្នាំ 2024




- AWT- វគ្គបណ្តុះបណ្តាលជំនាញក្នុងការតាក់តែងមជ្ឈត្តវិនិច្ឆ័យ
- I7I8L1 - វគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការពាណិជ្ជកម្ម កម្រិតបឋម (ជំនាន់៧ & ៨ )
- I7I8L2 - វគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការពាណិជ្ជកម្ម កម្រិតមធ្យម (ជំនាន់៧ & ៨ )
- I7I8L3 - វគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការពាណិជ្ជកម្ម កម្រិតឧត្តម (ជំនាន់៧ & ៨ )
- CI1I2L1 - វគ្គបណ្តុះបណ្តាលជំនាញអ្នកតំណាងក្នុងដំណើរការមជ្ឈត្តការពាណិជ្ជកម្ម កម្រិតបឋម (ជំនាន់១ & ២ )

# ៣. ហេដ្ឋារចនាសម្ព័ន្ធរបស់ ម.ជ.ម.

ម.ជ.ម. មានចក្ខុវិស័យក្នុងការតាមឱ្យទាន់នូវការវិវឌ្ឍន៍ នៃមជ្ឈត្តការពាណិជ្ជកម្មទាំងក្នុងតំបន់ និងក្នុងសកលលោក ដើម្បីបម្រើដល់អ្នកប្រើប្រាស់ឱ្យកាន់តែប្រសើរ។ ម.ជ.ម. បានធ្វើការខិតខំក្នុងការធ្វើវិសោធនកម្ម នៃវិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មឆ្នាំ២០១៤ និងវិធានពាក់ព័ន្ធ ហើយបានអនុម័តឱ្យប្រើប្រាស់នូវវិធានស្តីពីមជ្ឈត្តការថ្មី នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។

## ០១ វិធានស្តីពីមជ្ឈត្តការឆ្នាំ ២០២១

មានការបន្ថែមមុខងារថ្មីៗមួយចំនួន រួមមានៈ

- មជ្ឈត្តករបន្ទាន់
- នីតិវិធីពន្លឿន
- សវនាការ/ការប្រជុំតាមប្រព័ន្ធអនឡាញ

## ០២ បទបញ្ជាផ្ទៃក្នុងឆ្នាំ ២០២១

វិធានផ្ទៃក្នុងមានសារៈសំខាន់សម្រាប់ការគ្រប់គ្រងរចនាសម្ព័ន្ធ ប្រតិបត្តិការ និងអភិបាលកិច្ចរបស់ ម.ជ.ម. ។ ប្រការមួយចំនួននៅក្នុងបទបញ្ជាផ្ទៃក្នុងឆ្នាំ ២០២១ ត្រូវបានធ្វើវិសោធនកម្ម ដើម្បីឱ្យស្របតាមវិធានស្តីពីមជ្ឈត្តការឆ្នាំ២០២១ របស់ ម.ជ.ម.។

## ០៣ ក្រមសីលធម៌សម្រាប់មជ្ឈត្តករឆ្នាំ ២០២១

ក្រមសីលធម៌នេះផ្តល់នូវគោលការណ៍ណែនាំអំពីសីលធម៌សម្រាប់មជ្ឈត្តករគ្រប់រូប ដែលបានចុះបញ្ជីជាសមាជិករបស់ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងមជ្ឈត្តករដែលបានតែងតាំងក្រោមវិធានមជ្ឈត្តការរបស់ ម.ជ.ម.។









មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) ត្រូវបានបង្កើត ឡើងក្នុងគោលបំណង និងក៏បានបង្ហាញពីភាពជោគជ័យនេះជាមួយសហគមន៍ធុរកិច្ចផងដែរ។ ម.ជ.ម. យល់ឃើញថា មិនមែនគ្រប់វិវាទពាណិជ្ជកម្មទាំងអស់ ចាំបាច់ត្រូវដោះស្រាយដោយសេចក្តីសម្រេចដែលចងកាតព្វកិច្ចនោះទេ។ ម.ជ.ម. យល់ឃើញថា សន្ធានកម្មគឺជាវិធីសាស្ត្រដោះស្រាយវិវាទមួយផ្សេងទៀត ដែលអាចផ្តល់នូវការដោះស្រាយវិវាទដោយសន្តិវិធី ដែលកើតឡើងនៅ ក្នុងបរិបទទំនាក់ទំនងពាណិជ្ជកម្ម។ សន្ធានកម្មគឺជាការដោះស្រាយវិវាទដែលមានលក្ខណៈក្រៅផ្លូវការ និងសម្ងាត់ ដែលតតិយជនអព្យាក្រឹត្យជួយអ្នកចូលរួមចំនួនពីរ ឬច្រើនរូបឱ្យបានយល់ពីចំណុចវិវាទ ផលប្រយោជន៍ និងតម្រូវការរបស់ពួកគេឱ្យកាន់តែច្បាស់ ហើយផ្តល់លទ្ធភាពដល់ពួកគេក្នុងការស្វែងរកចំណុចរួមចំពោះភាពខុសគ្នារបស់ពួកគេតាមរយៈកិច្ចព្រមព្រៀងដោយស្ម័គ្រចិត្ត។ ក្នុងគោលបំណងនេះ ម.ជ.ម. បានអនុម័តវិធានស្តីពីសន្ធានកម្មសម្រាប់ការដោះស្រាយវិវាទដោយសន្តិវិធីតាមរយៈសន្ធានកម្ម។ នៅពេលមានវិធានស្តីពីសន្ធានកម្មនេះ ម.ជ.ម. សង្ឃឹមថានឹងផ្តល់ជូននូវជម្រើសមួយផ្សេងទៀត ដើម្បីជួយធុរជនក្នុងការសម្រេចបាននូវដំណោះស្រាយទៅលើវិវាទរបស់ពួកគេដោយការចំណាយកម្រៃសេវា និងពេលវេលាប្រកបដោយប្រសិទ្ធភាព។

## ០១ វិធានស្តីពីសន្ធានកម្ម ឆ្នាំ២០២៣

ម.ជ.ម. បានអនុម័តវិធានស្តីពីសន្ធានកម្មសម្រាប់ការ ដោះស្រាយវិវាទដោយសន្តិវិធីតាមរយៈសន្ធានកម្ម។

## ០២ វិធានស្តីពីលក្ខណៈសម្បត្តិ និងការចុះបញ្ជីសន្ធានការីរបស់ ម.ជ.ម.

ដើម្បីផ្តល់ជូនគូភាគីនូវបញ្ជីសន្ធានការី ដែលបំពេញលក្ខណសម្បត្តិអប្បបរមា ដើម្បីចុះបញ្ជីនៅក្នុងបញ្ជីសន្ធានការីរបស់ ម.ជ.ម. ។

## ០៣ ក្រមសីលធម៌សម្រាប់សន្ធានការី របស់ ម.ជ.ម.

ក្រមសីលធម៌ជាផ្នែកមួយនៃវិធានស្តីពីសន្ធានកម្មរបស់ ម.ជ.ម. និងអាចត្រូវបានកែសម្រួលដោយឡែក ពីវិធានស្តីពីសន្ធានកម្ម។









# ៤. របាយការណ៍សកម្មភាព ម.ជ.ម.

ម.ជ.ម. បានរៀបចំ និងសហការរៀបចំកម្មវិធីសរុបចំនួន ៣១ ពីដើមឆ្នាំ២០២៣ រហូតមកដល់ ខែកុម្ភៈ ឆ្នាំ២០២៤ នេះ គ្រប់កម្មវិធីបានបញ្ចប់ជាស្ថាពរ និងប្រព្រឹត្តទៅដោយរលូនដែលមានអ្នកចូលរួមសរុបច្រើនជាង ២០០០ រូបមកពីវិស័យផ្សេងៗរួមមាន វិស័យធុរៈកិច្ច និងសមាគមន៍វិជ្ជាជីវៈ ក្រសួងពាក់ព័ន្ធ ស្ថាប័នអប់រំក្នុងព្រះរាជាណាចក្រកម្ពុជា និងពីបណ្តាប្រទេសផ្សេងៗផងដែរ។



### ២២ កុម្ភៈ ២០២៣ | ការពិគ្រោះយោបល់ជាសាធារណៈទៅលើវិធានស្តីពីសន្ទានកម្ម និងក្រមសីលធម៌របស់សន្ទានការីបេស់ ម.ជ.ម.

នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានសហការរៀបចំសិក្ខាសាលាស្តីអំពី៖ "ការពិគ្រោះយោបល់ជាសាធារណៈទៅលើវិធានស្តីពីសន្ទានកម្ម និងក្រមសីលធម៌របស់សន្ទានការី" ជាមួយនឹងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដោយមានការគាំទ្រពី Swiss Cooperation Office and Consular Agency នៃព្រះរាជាណាចក្រកម្ពុជា (Swiss Confederation)។

### សិក្ខាសាលាអនឡាញស្តីពីតួនាទីរបស់អ្នកតំណាងក្នុងដំណើរការមជ្ឈត្តការ | ២៤ កុម្ភៈ ២០២៣




កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៤ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានធ្វើការបើកវគ្គបណ្តុះបណ្តាលស្តីពីជំនាញអ្នកតំណាងក្នុងដំណើរការមជ្ឈត្តការ ជំនាន់១ កម្រិតបឋម ដែលនឹងចាប់ផ្តើមនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៣។ ជាមួយគ្នានេះដែរ ម.ជ.ម. មានកិត្តិយសក្នុងការអញ្ជើញវាគ្មិន លោកមជ្ឈត្តករ សាន គីរី និង លោកមជ្ឈត្តករ គឹម សាន ដើម្បីធ្វើបទបង្ហាញលម្អិតអំពីតួនាទីរបស់អ្នកតំណាងក្នុងដំណើរការមជ្ឈត្តការ។



### ១៨ មីនា ២០២៣ | មហាសន្និបាតប្រចាំឆ្នាំលើកទី៩ របស់ ម.ជ.ម.

កាលពីថ្ងៃសៅរ៍ ១២រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានរៀបចំកិច្ចប្រជុំមហាសន្និបាតប្រចាំឆ្នាំលើកទី៩ របស ម.ជ.ម. នៅសណ្ឋាគាររ៉េស៊ីដង់ សុខា ភ្នំពេញ ក្រោមអធិបតីភាពរបស់លោកមជ្ឈត្តករ សាន គីរី ប្រធាន ម.ជ.ម.។



**២៩ មីនា ២០២៣**

## ដំណើរទស្សនកិច្ចសិក្សារបស់និស្សិត CAMED Business School

នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ លោកមជ្ឈត្តករ សាន គីរី ប្រធាន ម.ជ.ម. បានទទួលស្វាគមន៍ដំណើរទស្សនកិច្ចសិក្សារបស់និស្សិតចំនួន ២៤ រូប នៃសាលា CamEd Business School ដែលដឹកនាំដោយ លោកសាស្ត្រាចារ្យបណ្ឌិត ហាប់ ផល្លី និងលោកសាស្ត្រាចារ្យ ហូរ វរៈបុត្ត នៅទីស្នាក់ការមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ( ម.ជ.ម.) ក្នុងគោលបំណងបង្កើននូវចំណេះដឹងផ្នែកមជ្ឈត្តការនៅកម្ពុជាឱ្យកាន់តែលម្អិត និងបណ្តុះស្មារតីនិស្សិតឱ្យយល់ដឹងកាន់តែច្បាស់អំពីសក្តានុពលនៃមជ្ឈត្តការក្នុងវិស័យពាណិជ្ជកម្ម។

## តួនាទី និងប្រសិទ្ធភាពរបស់ ម.ជ.ម. និងក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

**០៤ មេសា ២០២៣**

នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) CAMFEBA និងក្រុមប្រឹក្សាអាជ្ញាកណ្តាល (AC) បានសហការរៀបចំវេទិកាពិភាក្សាមួយក្រោមប្រធានបទស្តីពី “តួនាទី និងប្រសិទ្ធភាពរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ”។





**០៦ មេសា ២០២៣**

## សិក្ខាសាលា ស្តីពីសេចក្តីណែនាំអំពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) និងវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវនៃក្រសួងពាណិជ្ជកម្ម បានសហការរៀបចំសិក្ខាសាសាស្តីពី “សេចក្តីណែនាំអំពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា”។ លោកមជ្ឈត្តករ គឹម សាន អនុប្រធាន ម.ជ.ម. បានផ្តល់កិត្តិយសក្នុងការថ្លែងសន្ទរកថាស្វាគមន៍ដល់អង្គសិក្ខាសាលាទាំងមូល ព្រមជាមួយមានវត្តមាន លោកជំទាវ គង់ សិទ្ធិកា អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម បានអញ្ជើញជាអធិបតីភាពក្នុងពិធីបើកសិក្ខាសាលានេះផងដែរ។

## ម.ជ.ម. ចូលរួមសន្និសីទស្តីពី មជ្ឈត្តកម្មសំណង់អន្តរជាតិឆ្នាំ ២០២៣ ទីក្រុងហូជីមិញ

**១៧ មេសា ២០២៣**

ថ្ងៃទី១៧ ខែមេសា ឆ្នាំ ២០២៣ ម.ជ.ម. បានចូលរួមសន្និសីទស្តីពី “មជ្ឈត្តកម្មសំណង់អន្តរជាតិឆ្នាំ ២០២៣ ទីក្រុងហូជីមិញ (HICAC 2023)” តំណាងដោយកញ្ញា ម៉ាត់ ហ្វានីតា អគ្គលេខាធិការរបស់ ម.ជ.ម. ។សន្និសិទនេះត្រូវបានរៀបចំឡើងដោយ Society of Construction Law Vietnam ដែលមានគោលបំណងប្រមូលផ្តុំអ្នកជំនាញមកពីឧស្សាហកម្មសំណង់ អ្នកជំនាញច្បាប់ មជ្ឈត្តករ និងអ្នកសិក្សាស្រាវជ្រាវ ដើម្បីពិភាក្សាអំពីនិន្នាការ ការអនុវត្ត និងការអភិវឌ្ឍន៍ចុងក្រោយបង្អស់ក្នុងមជ្ឈត្តកម្មសំណង់។





## ១១ ឧសភា ២០២៣ | សិក្ខាសាលាអំពីដំណាក់កាលសំខាន់ៗក្នុងដំណើរការមជ្ឈត្តការ

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) នៃព្រះរាជាណាចក្រកម្ពុជា បានសហការជាមួយនឹងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជារៀបចំនូវសិក្ខាសាលាមួយក្រោមប្រធានបទស្តីពី "ដំណាក់កាលសំខាន់ៗក្នុងដំណើរការមជ្ឈត្តការ" ដែលមានវត្តមានលោកមជ្ឈត្តករ សាន គីរី ប្រធាន ម.ជ.ម. និងលោកមជ្ឈត្តករ គឹម សាន អនុប្រធាន ម.ជ.ម. បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយស ព្រមទាំងមានវត្តមាន ឯកឧត្តម លី ច័ន្ទតុលា ប្រធានគណៈមេធាវីបានអញ្ជើញធ្វើសេចក្តីថ្លែងសុន្ទរកថាបើកសិក្ខាសាលា។

## ការជ្រើសតាំង តួនាទី និងកាតព្វកិច្ចនៃវេទិកាមជ្ឈត្តកម្មនៅក្នុងប្រទេសកម្ពុជា និងប្រទេសជប៉ុន | ២៧ ឧសភា ២០២៣

ម.ជ.ម. បានសហការជាមួយកម្មវិធីសិក្សាថ្នាក់អនុបណ្ឌិតនីតិសាស្ត្រជាភាសាអង់គ្លេស ថ្នាក់សិក្សាស្រាវជ្រាវផ្នែក "Decolonizing Arbitration" នៃសាកលវិទ្យាល័យណាហ្គូយ៉ា និងសមាគមមជ្ឈត្តការពាណិជ្ជកម្មជប៉ុន (JCAA) បានរៀបចំសិក្ខាសិលាមួយក្រោមប្រធានបទស្តីពី "ការជ្រើសតាំង តួនាទី និងកាតព្វកិច្ចនៃវេទិកាមជ្ឈត្តកម្មនៅក្នុងប្រទេសកម្ពុជា និងប្រទេសជប៉ុន" សិក្ខាសាលានេះមានវត្តមានលោកមជ្ឈត្តករ សាន គិរី ប្រធាន ម.ជ.ម. ចូលរួមជាវាគ្មិនកិត្តិយស ក្នុងកិច្ចពិភាក្សា អំពីបញ្ហានីតិវិធីសំខាន់ៗដែលអាចកើតឡើងក្នុងដំណើរការមជ្ឈត្តកម្ម។





## ២៤ មិថុនា ២០២៣ | វគ្គបណ្តុះបណ្តាលជំនាញអ្នកតំណាងក្នុងដំណើរការមជ្ឈត្តការ និងជំនាញមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

វគ្គបណ្តុះបណ្តាលកម្រិតបឋមនៃជំនាញជាអ្នកតំណាងក្នុងដំណើរការមជ្ឈត្តការ។ ម.ជ.ម. បានរៀបចំវគ្គបណ្តុះបណ្តាលកម្រិតបឋមនៃជំនាញជាអ្នកតំណាងក្នុងដំណើរការមជ្ឈត្តការ ជំនាន់១ និងជំនាញមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ជំនាន់៧ ដែលដឹកនាំបង្រៀនដោយគ្រូឧទ្ទេសដែលមានជំនាញវិជ្ជាជីវៈ ជាច្រើនរូប របស់ ម.ជ.ម. និងពីបណ្តាស្ថាប័នពាក់ព័ន្ធ។

## សិក្ខាសាលាអនឡាញ ស្តីពីវិជ្ជាជីវៈមជ្ឈត្តករ និង អ្នកតំណាងក្នុងដំណើរការមជ្ឈត្តការ | ២០ កក្កដា ២០២៣

ម.ជ.ម. បានរៀបចំសិក្ខាសិលាអនឡាញមួយស្តីអំពី "វិជ្ជាជីវៈមជ្ឈត្តករ និងអ្នកតំណាងក្នុងដំណើរការមជ្ឈត្តការ" នៅថ្ងៃព្រហស្បតិ៍ ទី២០ ខែកក្កដា ឆ្នាំ២០២៣ ។ ម.ជ.ម. មានកិត្តិយសក្នុងការអញ្ជើញ លោកមជ្ឈត្តករ សាន គីរី ប្រធាន ម.ជ.ម. និងលោកមជ្ឈត្តករ ប៊ុន យូឌី នាយកគ្រប់គ្រង ការិយាល័យមេធាវី ប៊ុន និងសហការី ចូលរួមជាវាគ្មិនកិត្តិយសដើម្បីធ្វើបទបង្ហាញលម្អិត ព្រមទាំងចែករំលែកចំណេះដឹង ក៏ដូចជាបទពិសោធន៍នៅក្នុងវិជ្ជាជីវៈជាមជ្ឈត្តករ ក៏ដូចជាអ្នកតំណាងក្នុងដំណើរការមជ្ឈត្តការ។





## ២៦ កក្កដា ២០២៣ | សិក្ខាសាលាអនឡាញស្តីពីការណែនាំ និងការចែករំលែកបទពិសោធន៍អំពីកម្មវិធីប្រកួតមជ្ឈត្តការប្រតិដ្ឋ

ម.ជ.ម. បានធ្វើការរៀបចំនូវសិក្ខាសាលាអនឡាញមួយស្តីអំពី "ការណែនាំ និងការចែករំលែកបទពិសោធន៍អំពីកម្មវិធីប្រកួតមជ្ឈត្តការប្រតិដ្ឋផ្នែកពាណិជ្ជកម្មប្រចាំឆ្នាំរបស់ ម.ជ.ម." ដែលនឹងប្រព្រឹត្តឡើង នៅថ្ងៃពុធ ទី២៦ ខែកក្កដា ឆ្នាំ២០២៣ ខាងមុខនេះ។ ម.ជ.ម. មានកិត្តិយសក្នុងការអញ្ជើញវាគ្មិនកិត្តិយស លោកស្រីបណ្ឌិត ម៉ែន វុឌ្ឍិការណ៍ ព្រមទាំងមានការអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសដោយ កញ្ញាមេធាវី សារិន មាសរក្សា និងកញ្ញាមេធាវី កៅ ច័ន្ទបញ្ញាវត្តី ផងដែរ។

## ពិធីដាក់ឱ្យដំណើរការនូវសេវាសន្ទានកម្មពាណិជ្ជកម្មរបស់ម.ជ.ម. | ១៨ កញ្ញា ២០២៣

ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ម.ជ.ម. បានរៀបចំពិធីដាក់ឱ្យដំណើរការនូវសេវាសន្ទានកម្មពាណិជ្ជកម្មរបស់ ម.ជ.ម. ដែលចូលរួមសហការឧបត្ថម្ភដោយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងការិយាល័យសហប្រតិបត្តិការណ៍ស្វីស និងទីភ្នាក់ងារកុងស៊ុលនៅកម្ពុជា។





## ៣០ កញ្ញា ២០២៣ | ការណែនាំអំពីដំណើរការប្រកួតមជ្ឈត្តការប្រតិដ្ឋផ្នែកពាណិជ្ជកម្មប្រចាំឆ្នាំលើកទី៣

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានរៀបចំសិក្ខាសាលា៖ ស្តីពីការណែនាំអំពី ដំណើរការប្រកួតមជ្ឈត្តការប្រតិដ្ឋផ្នែកពាណិជ្ជកម្មប្រចាំឆ្នាំលើកទី៣ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ ។

## សិក្ខាសាលាស្តីអំពី វេទិកាដោះស្រាយវិវាទមជ្ឈត្តការផ្នែកពាណិជ្ជកម្ម | ២១ តុលា ២០២៣

សាកលវិទ្យាល័យជាតិគ្រប់គ្រង បានសហការជាមួយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងក្រុមហ៊ុន ឌី អេហ្វ ឌី អិលមេគង្គ(ខេមបូឌា) បានរៀបចំកម្មវិធីជជែកអំពីធុរកិច្ចលើកទី១០ស្តីពី "វេទិកាដោះស្រាយវិវាទ៖ មជ្ឈត្តការផ្នែកពាណិជ្ជកម្ម" នៅសាលប្រជុំ B នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង។






## ២៧ តុលា ២០២៣ | វិធីសាស្ត្រក្លាយជាអ្នកតំណាងឆ្នើមនៅក្នុងដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានរៀបចំសិក្ខាសាលាស្ដីអំពី៖ "វិធីសាស្ត្រក្លាយជាអ្នកតំណាងឆ្នើមនៅក្នុងដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម"។
ជាមួយគ្នានេះដែរ ម.ជ.ម. មានកិត្តិយសក្នុងការអញ្ជើញវាគ្មិនកិត្តិយស លោកមជ្ឈត្តករ គឹម សាន អនុប្រធាន ម.ជ.ម. ដើម្បីធ្វើបទបង្ហាញលម្អិតអំពីវិធីសាស្ត្រនានាដើម្បីក្លាយជាអ្នកតំណាងឆ្នើមនៅក្នុងដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

## វគ្គបណ្តុះបណ្តាលស្តីអំពីការគ្រប់គ្រងសំណុំរឿង និងការត្រួតពិនិត្យមជ្ឈត្តវិនិច្ឆ័យនៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មសឹង្ហបុរី | ២៧ វិច្ឆិកា ២០២៣




នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារអគ្គលេខាធិការដ្ឋាននៃ ម.ជ.ម. ក្រោមការដឹកនាំរបស់កញ្ញា ម៉ាត់ ហ្វានីតា អគ្គលេខាធិការនៃ ម.ជ.ម. បានចូលរួមវគ្គបណ្តុះបណ្តាលស្តីអំពីការគ្រប់គ្រងសំណុំរឿង និងការត្រួតពិនិត្យមជ្ឈត្តវិនិច្ឆ័យ ដែលរៀបចំដោយមជ្ឈមណ្ឌលមជ្ឈត្តកម្មអន្តរជាតិសិង្ហបុរី (SIAC) ដឹកនាំដោយលោក Kevin NASH ដែលជាមន្ត្រីចុះបញ្ជីនៅ SIAC។




## ២៨ វិច្ឆិកា ២០២៣ | ដំណើរទស្សនកិច្ចរបស់ ម.ជ.ម. នៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មសឹង្ហបុរី

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារអគ្គលេខាធិការដ្ឋានក្រោមការដឹកនាំរបស់ កញ្ញា ម៉ាត់ ហ្វានីតា អគ្គលេខាធិការ ម.ជ.ម. បានចូលរួមវគ្គបណ្តុះបណ្តាលស្តីអំពីការសន្ទានកម្ម ដែលរៀបចំដោយមជ្ឈមណ្ឌលសន្ទានកម្មប្រទេសសិង្ហបុរី (SMC)។

## សិក្ខាសាលាអនឡាញ ស្តីពីការណែនាំអំពីដំណើរការប្រកួតមជ្ឈត្តការប្រតិដ្ឋផ្នែកពាណិជ្ជកម្មប្រចាំឆ្នាំលើកទី៣ | ១៥ ធ្នូ ២០២៣




នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានរៀបចំសិក្ខាសាលា៖ ស្តីពីការណែនាំអំពីដំណើរការប្រកួតមជ្ឈត្តការប្រតិដ្ឋផ្នែកពាណិជ្ជកម្មប្រចាំឆ្នាំលើកទី៣ ។



**២១ ធ្នូ ២០២៣**

## ក្រុមប្រឹក្សាប្រតិបត្តិស្វាគមន៍គណៈប្រតិភូមកពី CCPIT Yunnan

នាព្រឹកថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៣ លោកមជ្ឈត្តករ គឹម សាន អនុប្រធាន ម.ជ.ម. និងលោកមជ្ឈត្តករ តែ ពន្លឺ សមាជិកក្រុមប្រឹក្សាប្រតិបត្តិនៃ ម.ជ.ម. បានទទួលស្វាគមន៍គណៈប្រតិភូមកពីក្រុមប្រឹក្សារង CCPIT Yunnan ក្រោមការដឹកនាំរបស់លោក LI Rengui, អគ្គលេខាធិការ។ ក្រុមប្រឹក្សារងនៃ CCPIT Yunnan គឺជាអង្គការអាជីវកម្មក្នុងស្រុក និងជាក្រុមហ៊ុននៅក្នុងទីក្រុង Kunming មួយដែលមានចក្ខុវិស័យក្នុងការអភិវឌ្ឍ និងបន្តស្វែងរកផលប្រយោជន៍ដល់ក្រុមហ៊ុនក្នុងស្រុក និងអាជីវកម្មនៅក្នុងប្រទេសចិន។

## ពិធីបើកវគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ជំនាន់៧ និងជំនាន់៨ «កម្រិតមធ្យម»

**០៦ មករា ២០២៤**

នាព្រឹកថ្ងៃសៅរ៍ ទី០៦ ខែមករា ឆ្នាំ២០២៤ ម.ជ.ម. បានរៀបចំដំណើរការបើកវគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ជំនាន់៧ និងជំនាន់៨ «កម្រិតមធ្យម»។ ការរៀបចំនូវវគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការផ្នែកពាណិជ្ជកម្មនេះ ជាសកម្មភាពមួយក្នុងចំណោមសកម្មភាពនានា ដែលមជ្ឈមណ្ឌលខិតខំជម្រុញបន្ថែម ក្នុងគោលបំណងដើម្បីសម្រេចឱ្យបាននូវបេសកម្មរបស់ខ្លួន ក្នុងការធានាគុណភាពនៃដំណើរការមជ្ឈត្តការនៅកម្ពុជា។





**១០ មករា ២០២៤**

## ពិធីអបអរសាទរខួបគម្រប់១០ឆ្នាំនៃការបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

នៅព្រឹកថ្ងៃពុធ ១៤ រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ២៥៦៧ ត្រូវនឹងថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មបានប្រារព្ធពិធីអបអរសាទរខួបគម្រប់១០ឆ្នាំនៃការបង្កើត ម.ជ.ម.។ អង្គពិធីប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម បួន សារៈមុនី រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងលោកមជ្ឈត្តករ សាន គីរី ប្រធាននៃ ម.ជ.ម.

## កិច្ចប្រជុំផ្សព្វផ្សាយស្តីពីកិច្ចដំណើរការនៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ដ.ក.)

**១៥ មករា ២០២៤**

លោកសាន គីរី ប្រធាន ម.ជ.ម. លោក គឹម សាន អនុប្រធាន ម.ជ.ម. និងកញ្ញា ម៉ាត់ ហ្វានីតា អគ្គលេខាធិការនៃ ម.ជ.ម. បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយស្តីពីកិច្ចដំណើរការនៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ដ.ក.) ដល់អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍ នៅបណ្ណិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ដែលសហការរៀបចំដោយ អ.ដ.ក និង Oxfam ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធាននៃ (អ.ដ.ក.) ។






## ១៧ មករា ២០២៤ | ការថ្លែងអំណរគុណចំពោះលោក Johnny Tan

ម.ជ.ម. បានប្រារព្ធការថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះលោក Johnny Tan សមាជិកមជ្ឈត្តកររបស់ ម.ជ.ម. និងជាសមាជិកក្រុមប្រឹក្សាប្រឹក្សាពិគ្រោះយោបល់ ចំពោះការរួមចំណែករបស់លោកសម្រាប់រយៈពេល ១៣ឆ្នាំ។ លោក Johnny Tan គឺជាទ្រព្យដែលមិនអាចកាត់ថ្លៃបានចំពោះ ម.ជ.ម. ជាមួយនឹងបទពិសោធន៍របស់លោកជាង ៣០ឆ្នាំ នៅក្នុងវិស័យមជ្ឈត្តការ ដែលបង្ហាញអំពីការយកចិត្តទុកដាក់ឥតងាករេ និងការប្តេជ្ញាចិត្តដ៏មុតមាំរបស់លោក ចំពោះការរីកចម្រើននៃមជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា។

## ការដោះស្រាយវិវាទពាណិជ្ជកម្ម និងយុទ្ធសាស្ត្រនៃការគ្រប់គ្រងបំណុលក្នុងអាជីវកម្ម | ២៣ មករា ២០២៤

នាថ្ងៃអង្គារ ទី២៣ ខែមករា ឆ្នាំ២០២៤ លោកមជ្ឈត្តករ គឹម សាន អនុប្រធានមជ្ឈមណ្ឌលមជ្ឈត្តកម្មពាណិជ្ជកម្មជាតិ (ម.ជ.ម.) និងកញ្ញា ម៉ាត់ ហ្វានីតា អគ្គលេខាធិការនៃ ម.ជ.ម. បានចូលរួមថ្លែងសុន្ទរកថាក្នុងសិក្ខាសាលាស្ដីអំពី "ការដោះស្រាយវិវាទពាណិជ្ជកម្ម និងយុទ្ធសាស្ត្រនៃការគ្រប់គ្រងបំណុលក្នុងអាជីវកម្ម" ដែលរៀបចំដោយ សភាពាណិជ្ជកម្មសៀមរាប-ឧត្តរមានជ័យ និង ARISE Plus Cambod ia នៅខេត្តសៀមរាប។






## ២៦ មករា ២០២៤ | ជំនួបពិភាក្សាការងារជាមួយលោក ហោ អៀងឆាយ ប្រធាននៃវិទ្យាស្ថានបណ្ដុះបណ្ដាលពាណិជ្ជកម្ម និងស្រាវជ្រាវ

នារសៀលថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤ កញ្ញា ម៉ាត់ ហ្វានីតា អគ្គលេខាធិការនៃ ម.ជ.ម. និងលោក ឃុត ឧត្តម អ្នកគ្រប់គ្រងសំណុំរឿងនៃ ម.ជ.ម. បានជំនួបពិភាក្សាការងារ និងនាំយកនូវសៀវភៅមួយចំនួនរបស់ ម.ជ.ម. ជូនដល់វិទ្យាស្ថានបណ្ដុះបណ្ដាលពាណិជ្ជកម្ម និងស្រាវជ្រាវនៃក្រសួងពាណិជ្ជកម្ម។

## ដំណើរការបើក និងផ្លូវផ្តងក្រុមនៃកម្មវិធីប្រកួតមជ្ឈត្តការប្រតិដ្ឋផ្នែកពាណិជ្ជកម្មប្រចាំឆ្នាំលើកទី៣ របស់ ម.ជ.ម. ឆ្នាំ២០២៣ | ២៧ មករា ២០២៤

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម. ) បានរៀបចំដំណើរការបើក និងផ្លូវផ្តងក្រុមនៃកម្មវិធីប្រកួតមជ្ឈត្តការប្រតិដ្ឋផ្នែកពាណិជ្ជកម្មប្រចាំឆ្នាំលើកទី៣របស់ ម.ជ.ម. ឆ្នាំ២០២៣ ក្រោមអធិបតីភាពរបស់លោកមជ្ឈត្តករ សាន គីរី ប្រធាន ម.ជ.ម. និងជាប្រធានក្រុមការងាររៀបចំការប្រកួត និងមានកិត្តិយសអញ្ជើញចូលរួមដោយ លោកមជ្ឈត្តករ គឹម សាន អនុប្រធាន ម.ជ.ម. និងលោកមជ្ឈត្តករ សូ មូស្សេន្ទី សមាជិកក្រុមប្រឹក្សាប្រតិបត្តិ និងជាគណៈកម្មការនិពន្ធសំណុំរឿងប្រតិដ្ឋ។





## ២៨ មករា ២០២៤ | វគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានរៀបចំវគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ជំនាន់៧ និងជំនាន់៨ «កម្រិតមធ្យម» ដែលដឹកនាំបង្រៀនដោយគ្រូឧទ្ទេសដែលមានជំនាញវិជ្ជាជីវៈ ជាច្រើនរូប របស់ ម.ជ.ម. និងពីបណ្តាស្ថាប័នពាក់ព័ន្ធ។

## ការណែនាំអំពីសេវាសន្ទានកម្មរបស់ ម.ជ.ម. | ០២ កុម្ភៈ ២០២៤

នាថ្ងៃសុក្រ ទី០២ ខែកុម្ភៈ ឆ្នាំ២០២៤ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានរៀបចំនូវសិក្ខាសិលាអនឡាញមួយស្តីអំពី "ការណែនាំអំពីសេវាសន្ទានកម្មរបស់ ម.ជ.ម." ។ ដែលមានវត្តមាន លោកមជ្ឈត្តករ សាន គីរី ប្រធាន ម.ជ.ម. ចូលរួមជាវាគ្មិនកិត្តិយសដើម្បីធ្វើបទបង្ហាញលម្អិត ព្រមទាំងចែករំលែកចំណេះដឹងនានាទាក់ទងនឹងសេវាសន្ទានកម្ម ក៏ដូចជាវិជ្ជាជីវៈជាសន្ទានការីចុះបញ្ជី ក្នុងសិក្ខាសិលានេះ។





## ០៣ កុម្ភៈ ២០២៤ | ការប្រឡងបញ្ចប់នៃវគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ជំនាន់ ៧និង៨ កម្រិតមធ្យម

នាថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៤ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានរៀបចំការប្រឡងបញ្ចប់នៃវគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ជំនាន់៧ និងជំនាន់៨ «កម្រិតមធ្យម» ដែលមាន លោកមជ្ឈត្តករ សាន គីរី ប្រធាន ម.ជ.ម. ជាប្រធានគណៈមេប្រយោគ និងលោកមជ្ឈត្តករ លឹម វាសនា អគ្គហេរញ្ញិក ម.ជ.ម. ជាគណៈកម្មការអនុរក្ស។

## ពិធីចុះអនុស្សារណៈនៃការយោគយល់គ្នារវាង ម.ជ.ម. និង ELBBL | ២១ កុម្ភៈ ២០២៤

នារសៀលថ្ងៃពុធ ១២កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ម.ជ.ម. និង ELBBL បានរៀបចំពិធីចុះអនុស្សារណៈនៃការយោគយល់គ្នា ដែលបានប្រព្រឹត្តទៅនៅទីស្នាក់ការ របស់ ម.ជ.ម. ក្រោមអធិបតីភាពរបស់លោកមជ្ឈត្តករ សាន គីរី ប្រធាន ម.ជ.ម. និងលោកស្រី Margaret Ryan នាយកថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ជាភាសាអង់គ្លេស និងការចូលរួមពីបណ្តាថ្នាក់ដឹកនាំនៃស្ថាប័នទាំងពីរ។



# ៥. គោលបំណងរបស់ ម.ជ.ម.

## ចក្ខុវិស័យរបស់ ម.ជ.ម. គឺធ្វើឱ្យបរិយាកាសធុរកិច្ចរួមចំណែកដល់កំណើនសេដ្ឋកិច្ច និងសង្គមប្រកបដោយសមធម៌នៅកម្ពុជា។

ម.ជ.ម. មានបេសកកម្មក្នុងការក្លាយជាស្ថាប័នមជ្ឈត្តការពាណិជ្ជកម្មដែលអព្យាក្រឹត មិនលំអៀង ចំណេញពេលវេលា និងចំណាយតិចឈានមុខគេនៅកម្ពុជា។ គោលដៅរបស់ ម.ជ.ម. រួមមាន៖

- ទទួលបានការជឿទុកចិត្តកាន់តែប្រសើរពីវិស័យសាធារណៈ និងឯកជនទាំងក្នុងស្រុក និងអន្តរជាតិ
- សហការណ៍ជាមួយដៃគូពាក់ព័ន្ធទាំងអស់ ដើម្បីធ្វើឱ្យប្រទេសកម្ពុជាក្លាយជាយុត្តាធិការមួយដែលស្វាគមន៍ផ្នែកមជ្ឈត្តការ
- បង្កើនការចូលរួមរបស់ ម.ជ.ម. និងបង្ហាញពីកម្ពុជាជាលក្ខណៈអន្តរជាតិ ដើម្បីពង្រីកប្រតិបត្តិការឱ្យកាន់តែទូលំទូលាយបន្ថែមទៀត
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធចាំបាច់សម្រាប់ប្រតិបត្តិការ និងការអភិវឌ្ឍប្រកបដោយចីរភាព។

**ម.ជ.ម.** មជ្ឈត្តវិនិច្ឆ័យ, ដែលអាចអនុវត្តបានហួសពីដែនយុត្តាធិការជាតិ!

# TABLE OF CONTENTS

About NCAC

Case Management

Infrastructures

NCAC Activities

NCAC Goals

# 1. ABOUT NCAC

National Commercial Arbitration Centre (NCAC) was established by Law on Commercial Arbitration promulgated by Royal Decree No. NS/RKM/0506/010 dated 05 May 2006.

In pursuant to such law, the Royal Government of Cambodia issued Sub-Decree No. 124 ANKr.PK dated 12 August 2009 on the Organization and Functioning of the National Commercial Arbitration Centre and Sub-decree No. 182 ANKr.PK dated 31 December 2010 on the Amendments of the Sub-Decree No. 124 ANKr.PK.



# MESSAGE FROM PRESIDENT

I like to begin by expressing my gratitude to everyone involved in the establishment of the National Commercial Arbitration Centre (NCAC) of Cambodia, namely the leadership at the Ministry of Commerce, business communities, IFC being the donor supporting the initial training, the many experienced trainers dispatched by SIArb and SIAC, current and former colleagues at the General Secretariat, the Executive Board as well as fellow arbitrators. Without their unwavering support, encouragement, and dedication, NCAC would not be what it is today.

---

NCAC was born out of the desire to enhance the use of alternative dispute resolution (ADR) in Cambodia and to handle the increasing number of international and domestic commercial disputes which is correlated with the unprecedented economy growth in Cambodia. Foreign investments play an important role in contributing to the economy growth as well as the tremendous increase of cross border commercial deals. What the business communities need is the ability to resolve any dispute arising out of those transactions effectively through a neutral dispute resolution mechanism. A mechanism which can offer parties the autonomy to choose how the dispute should be resolved; the liberty to select the right persons equipped with the necessary technical know-how to decide on the case; and the ability to adopt a procedure that works best in settling their disputes based on the commercial nature of the deals. The ability to resolve disputes in confidence and to enforce the decision globally is also equally important to the business communities. Using arbitration is the way forward to addressing this business demand.



**"NCAC will continue in its strive to build its reputation to be the preferred venue for dispute resolution, offering excellent, efficient and expeditious case administration.**

# NCAC STRUCTURE

NCAC is governed by the General Assembly and Executive Board.

GA

## General Assembly

General Assembly is attended by members who are natural persons and a representative of each legal entity.

EB

## Executive Board

Composition of Executive Board is elected from among NCAC members by the General Assembly. The President of Executive Board is the President of NCAC. Executive Board is elected every 3 years.

GS

## General Secretariat

The General Secretariat perform roles as prescribed by the Internal Rules namely case management, administration and finance, public relations, and training delivery. The General Secretariat team is composed of dynamic and passionate individuals who are skillful of necessary technical know-how with multilingual capabilities.

CO

## Committees

Committees are established by Executive Board in order to conduct specific assignments or projects. There are currently 4 committee have been established, such as: Education & Training Committee
Appointment & Proceedings Committee
Membership Committee and Disciplinary Committee

AB

## Advisor Council

The advisory Council is to provide information and expert advice to the NCAC on relevant issues, developments and trends, including with regard to international arbitration regulations, policies and best practices, national and international law and alternative dispute resolution mechanism, business and commercial practice, institution building and management, training and professional development.

# NCAC STRUCTURE




NCAC consist of 4 types of members, such as:

- Arbitrator Members
- Legal Entity Members
- Individual Associate Members
- Legal Entity Associate Members

Since its operation in 2013, NCAC has admitted Arbitrator Members in a total of 111 members, 80 are currently active and 10 Legal Entity Members:

1. American Chamber of Commerce
2. Cambodia Chamber of Commerce
3. Cambodia Federation of Employers and Business Association
4. European Chamber of Commerce in Cambodia
5. Textile, Apparel, Footwear & Travel goods Association in Cambodia
6. International Business Chamber of Cambodia
7. Chamber of Professional and Micro Enterprises of Cambodia
8. Bar Association of The Kingdom of Cambodia
9. The Cambodian Association for Mining and Exploration Companies
10. Korean Chamber of Commerce in Cambodia

# EXECUTIVE BOARD OF 4TH MANDATE




# NCAC GENERAL SECRETARIAT



# APPOINTMENT & PROCEEDINGS COMMIITTEE




# EDUCATION & TRAINING COMMITTEE



## MEMBERSHIP COMMITTEE




## DISCIPLINARY COMMITTEE



# 2. CASE MANAGEMENT

Since NCAC issued its first Arbitral award in 2017 until 2023, NCAC has issued a total number of 18 Arbitral Awards. None of NCAC Arbitral Award has been aside by Cambodian Court or any oversea jurisdictions.

Moreover, one of the Awards has been recognized and being enforced by the Singaporean High Court.

## NCAC Arbitral Award Statistics



## CASE STATISTIC




## CASE LOAD YEAR ON YEAR



## SECTORS IN DISPUTE




## PARTIES IN DISPUTE



# Arbitration Skills Training Course & Others

Sub-decree 124 also requires NCAC to provide services and training of other alternative dispute resolution mechanisms, to ensure high quality standards of arbitration are maintained in Cambodia.

---

## Number of participants in trainings

March 2023 - March 2024




- AWT- Award Writing Training Course
- I7I8L1 - Arbitration Skills Training Course Introductory Level (Intake 7 & 8)
- I7I8L2 - Arbitration Skills Training Course Intermediate Level (Intake 7 & 8)
- I7I8L3 - Arbitration Skills Training Course Advance Level (Intake 7 & 8)
- CI1I2L1 - Parties Representative in Arbitration Proceedings Skills Training Course (Intake 1 & 2)

# 3. NCAC INFRASTRUCTURES

NCAC with the aims to stay up to date with the reginal and global developments in commercial Arbitration as well as to better serve its users, the NCAC embarked on the process to amend its 2014 Rules and adopted the new Rules on 28 March 2021.

01

## NCAC 2021 Arbitration Rules

There are a few new features, include:

- Emergency Arbitrator
- Expedited Procedure
- Online Hearings/Meetings

02

## NCAC 2021 Internal Rules

Internal Rules are important for governing the structure, operation and governance of the NCAC. Some articles in the 2021 Internal Rules have been amended to be aligned with NCAC 2021 Arbitration Rules.

03

## NCAC 2021 Code of Conduct for Arbitrator

Provides the guiding principles on ethics for all arbitrators who have been registered as a member of NCAC and those who have been appointed under the NCAC Arbitration Rules.









National Commercial Arbitration Centre (NCAC) was established for the purpose and has proven to be a success with the business community. NCAC is mindful that not all commercial disputes need to resort to binding decisions. Mediation is an informal and confidential conflict resolution process in which an impartial third party facilitates two or more participants better understand their issues, interest, needs and empower them to bridge their differences through a voluntary agreement. For this purpose, NCAC has adopted the Mediation Rules and other related rules and regulations in place and hope to offer another alternative dispute resolution mechanism to help businesses reach a resolution in a cost and time effective manner.

## 01 NCAC 2023 Mediation Rules

NCAC adopted the Mediation Rules for amicable settlement of disputes through Mediation.

## 02 NCAC Rules on Qualifications and Registration of Mediator

To provide parties with a list of Mediators meeting minimum qualification criteria for registration in NCAC's List of Mediators.

## 03 NCAC 2023 Code of Conduct for Mediators

Forms an intergral part of Mediation Rules of NCAC and can be revised independently of the Mediation Rules.









# 4. NCAC ACTIVITIES

NCAC has conducted more than 31 events from the beginning of 2023 to February 2024 and have been successfully conducted with the over 2000 participants from various background, including: Business and Professional Associations, relevant ministries, Academic institutions in Cambodia and from overseas.



**22 Feb 2023** | **Public Consultation Workshop on Draft Mediation Rules and Code of Conducts for Mediator of NCAC**

On 22 February 2023, National Commercial Arbitration Centre (NCAC) and International Finance Corporation (IFC) co-organized a "Public Consultation Workshop on Draft Mediation Rules and Code of Conducts for Mediator of National Commercial Arbitration Centre" with the support from Swiss Cooperation Office and Consular Agency in Cambodia (Swiss Confederation).

**Webinar on Role of Party Representative in Arbitration Proceedings** | **24 Feb 2023**

On 24 February 2024, National Commercial Arbitration Centre (NCAC) was honored to have Mr. SAN Kiri, President of NCAC, and Mr. KIM San, Vice-president of NCAC as speakers to provide the presentation on the role of Party representative in arbitration proceedings.





**18 Mar 2023** | **9th Annual General Assembly of NCAC**

On 18 March 2023, National Commercial Arbitration Centre (NCAC) organised the 9th Annual General Assembly at SOKHA Phnom Penh Hotel & Residence presided by Mr. SAN Kiri, President of NCAC.



## 29 Mar 2023 | Study Tour at NCAC from CAMED Business School

On 29 March 2023, Mr. SAN Kiri, President of the NCAC welcomed a study tour of 24 students from CamEd Business School led by Prof. Dr. HAP Phalthy and Prof. HO Varabott at the National Commercial Arbitration Centre (NCAC). This study tour is aimed at increasing in-depth knowledge of arbitration in Cambodia and cultivating students' awareness of the potential of arbitration in commercial sector.

## The Role and Effectiveness of the NCAC and AC in ADR in Cambodia | 04 Apr 2023

On 04 April 2023, National Commercial Arbitration Centre (NCAC), Cambodian Federation of Employers and Business Associations (CAMFEBA) and the Arbitration Council (AC) co-organized a forum on "The Role and Effectiveness of the NCAC and AC in Alternative Dispute Resolution Mechanism in Cambodia".





## 06 Apr 2023 | Seminar on Introducing of Commercial Arbitration in Cambodia

On 06 April 2023, National Commercial Arbitration Centre (NCAC) and Trade Training and Research Institution (TTRI) co-organized a seminar on Introducing of Commercial Arbitration in Cambodia. The Seminar is honored by Mr. KIM San, Vice-president of NCAC to present on the welcoming and opening speech and Her Excellency KONG Sedhika Under Secretary of State of Commerce.

## NCAC Attended Ho Chi Minh City International Construction Arbitration Conference | 17 Apr 2023

On 17 April 2023, NCAC was honored to attend Ho Chi Minh City International Construction Arbitration Conference 2023 (HICAC 2023), represented by Ms. Fanita MATH, Secretary General of NCAC. The conference was organized by the Society of Construction Law Vietnam, which aims to bring together professionals & experts to discuss the latest trends, practices, and developments in construction arbitration.





## 11 May 2023 | Seminar on Introducing of the Main Stages in Arbitration Proceedings

On 11 May 2023, National Commercial Arbitration Centre (NCAC) and The Bar and Association of the Kingdom of Cambodia co-organized the seminar on “Introducing of the main stages in arbitration proceedings” by Mr. SAN Kiri, NCAC President and Mr. KIM San, NCAC Vice-president. Having had H.E LY Chantola, President of BAKC given his welcome remarks.

## Arbitral Tribunal Selection, Roles, and Duties in Cambodia and Japan | 27 May 2023

NCAC is pleased to inform the public that, NCAC in Cooperates with the English Language Based Master of Law (ELBML), the research unit on “Decolonizing Arbitration” at Nagoya University, and Japan Commercial Arbitration Association (JCAA) are organizing a hybrid Seminar on “Arbitral Tribunal Selection, Roles and Duties in Cambodia and Japan” that will take place on 27th May 2023. Mr. San Kiri, President of NCAC and arbitrator members of the NCAC will join as speakers to bring a discussion concerning the significant procedural issue that arise during the arbitration proceeding.





## 24 Jun 2023 | Party Representation and Commercial Arbitration Training Course

“Party Representation in Arbitration Proceeding Skills and Commercial Arbitration Skills Training Course. NCAC has conducted of the Introductory Level of Party Representation in Arbitration Proceeding Skills Intake 1 and Commercial Arbitration Skills Training Course Intake 7 trained by professionals from NCAC and other relevant institutions.

## Webinar on Arbitrator Profession and Party Representative in Arbitration Proceedings | 20 Jul 2023

NCAC hosted a webinar under the topic “Arbitrator Profession and Party Representative in Arbitration Proceedings” on Thursday, 20 July 2023. NCAC honored to invite Mr. SAN Kiri, President of NCAC and Mr. BUN Youdy, Managing Partner of Bun & Associates as our honorary guest speakers.





26 Jul 2023

## Webinar on Introduction and sharing experiences of Moot Event

NCAC conducted a webinar under the topic of "Introduction to NCAC Moot Competition & Experience sharing from Moot Champions" on Wednesday, 26 July 2023. NCAC is honored to invite Dr. MEN VuthyKa, along with, Ms. Sarin MeasReaksa and Ms. Kov Chan Panha Votey as guest speakers.

## Launch of NCAC Commercial Mediation Service

18 Sep 2023

On 18 September 2023, National Commercial Arbitration Centre (NCAC) announced the successful launch of NCAC Commercial Mediation Service. In collaboration with the International Finance Corporation (IFC) and Swiss Confederation.





30 Sep 2023

## Introducing about Moot Competition Proceedings

National Commercial Arbitration Centre (NCAC) hosted a webinar under the topic "Introducing about Moot Competition Proceedings" on 30 September 2023.

## Seminar on Dispute Resolution of Commercial Arbitration

21 Oct 2023

On 21 October 2023, National University of Management and National Commercial Arbitration Centre (NCAC) and DFDL Cambodia co-organized the discussion on Dispute Resolution of Commercial Arbitration at Building B of National University of Management (NUM).





## 27 Oct 2023 | Webinar on Key Factors to become an Outstanding Representative in Arbitration Proceedings

On 27 October 2023, National Commercial Arbitration Centre (NCAC) organized the Webinar under the topic: Key factors to become an outstanding representative in arbitration proceedings. The Webinar is honored to have Mr. KIM San, Vice-president of NCAC as a guest speaker.

## Training on Case Management and Scrutinization of Arbitral Award organized by SIAC | 27 Nov 2023




On 27 November 2023, NCAC General Secretariat Team under the direction of Ms. Fanita MATH, Secretary General of the NCAC attended a training session on Case Management and Scrutinization of Arbitral Award organized by SIAC led by Mr. Kevin NASH, the Registrar of SIAC.




## 28 Nov 2023 | Singapore Mediation Centre Visit

On 28 November 2023, General Secretariat Team under the direction of Ms. Fanita MATH, Secretary General of the NCAC attended a training session on Mediation organized by the Singapore Mediation Centre (SMC).

## Webinar on Introducing on the NCAC 3rd Annual Commercial Arbitration Moot Competition | 15 Dec 2023




On 15 December 2023, National Commercial Arbitration Centre (NCAC) conducted a webinar under the topic of: The Introducing on the NCAC 3rd Annual Commercial Arbitration Moot Competition. The webinar aimed to provide detailed insights on the Moot Competition Proceedings and its preparation.



## 21 Dec 2023 | Executive Board welcomed a delegation from the CCPIT

On 21 December 2023, Mr. KIM San, Vice President of NCAC and Mr. TE Ponloeu, member of the NCAC Executive Board, welcomed a delegation from the CCPIT Yunnan Sub-council under the direction of Mr. Li Rengui, Secretary General. The CCPIT Yunnan Sub Council is a local organization of businesses and companies in Kunming with the intention to develop and further the interests of local companies and businesses in China.

## Opening Ceremony of Commercial Arbitration Skills Training Course Intake 7 & 8 "Intermediate Level" | 06 Jan 2024

On 06 January 2024, National Commercial Arbitration Centre (NCAC) conducts the Opening ceremony of Arbitration Skills Training Course Intake 7 & 8 Intermediate Level presided by Mr. SAN Kiri, President of NCAC and Mr. BUN Youdy, Trainer. The organization of the Training is one of the activities the Centre strives to achieve its missions to ensure the quality of arbitration proceeding in Cambodia.





## 10 Jan 2024 | 10th Years Anniversary of NCAC

On 10 January 2024, National Commercial Arbitration Centre (NCAC) celebrated the 10th Anniversary of establishing the NCAC at Hyatt Regency Phnom Penh. The Ceremony was presided over by His Excellency Buon Sarakmony, Secretary of State of the Ministry of Commerce and High Representative of Lok Chumteav Cham nimul, Minister of Commerce and Mr. San Kiri, President of National Commercial Arbitration Centre.

## National Authority for Alternative Dispute Resolution Meeting in purpose of advertise the Proceedings | 15 Jan 2024

On 15 Janunary 2024, Mr. SAN Kiri, NCAC President, Mr. KIM San, NCAC Vice President, Ms. MATH Fanita, NCAC Secretary General, participated in the National Authority for Alternative Dispute Resolution Meeting in Purpose of advertise the Proceedings to all Civil Society Organization and Development Partnership at Royal Academy for Justice of Cambodia that conducted by O.D.R and Oxfam, preside by H.E KERT Rith, Minister of Ministry of Justice.






17 Jan 2024

## Appreciation for Mr. Johnny Tan

On 17 January 2024, NCAC extends its sincere appreciation to Mr. Johnny Tan, NCAC Arbitrator member and Advisory Board, for his outstanding contributions for an impressive 13 years. Mr. Tan has been an invaluable asset to the NCAC with his over 30 years' experience in Arbitration, demonstrating unwavering dedication and remarkable commitment to the advancement of commercial arbitration in Cambodia.

## Commercial Dispute Resolution

23 Jan 2023

On 23 January 2024, Mr. KIM San, Vice-President of the National Commercial Arbitration Centre (NCAC), and Ms. MATH Fanita, Secretary General of NCAC, were invited to speak at a Workshop on "Commercial Dispute Resolution & Business Debt Management Strategies" organized by SiemReap-OddarMeanchey Chamber of Commerce and ARISE Plus Cambodia at Sokhalay Angkor Residence, Seimreap Province.





26 Jan 2024

## Discussion between NCAC and Trade Training and Research Institution

On 26 January 2024, Ms. MATH Fanita, Secretary General of NCAC and Mr. KHUT Oudam, Case Manager of NCAC is honored to have the discussion and provide NCAC Books to Trade Training and Research Institution.

## Opening and Matching Group of NCAC 3rd Annual Commercial Arbitration Moot Competition

27 Jan 2024

On 27 January 2024, National Commercial Arbitration Centre (NCAC) has organized the Opening and Matching Group of NCAC Moot Competition honored by Mr. SAN Kiri, President of NCAC and President of Moot Competition Committee and honored joint by Mr. KIM San Vice-president of NCAC along with Mr. SO Mosseny, the member of the executive Board and the Moot Author.





## 28 Jan 2024 | Commercial Arbitration Skills Training Course

National Commercial Arbitration Centre (NCAC) has conducted the Commercial Arbitration Skills Training Course Intake 7 and Intake 8 "Intermediate Level" trained by professionals from NCAC and other relevant institutions.

## Introducing NCAC Mediation Service | 02 Feb 2024

On Friday 02 February 2024, National Commercial Arbitration Centre (NCAC) hosted a webinar under the topic “Introducing NCAC Mediation Service”. NCAC was honored to have Mr. SAN Kiri, President of NCAC as an honorary guest speaker. Our speaker provided an in-dept information on mediation service including the requirement for obtaining registration as a mediator.





## 03 Feb 2024 | Final Examination of Commercial Arbitration Skills Training Course Intake 7 & 8 Intermediate Level

On 03 February 2024, National Commercial Arbitration Centre (NCAC) organized a Final Examination of Commercial Arbitration Skills Training Course Intake 7 and Intake 8 "Intermediate Level" preside by Mr. SAN Kiri, President of NCAC as Chairman of the examination committee and Mr. LIM Veasna, Treasurer of NCAC as examination invigilator.

## MoU Signing Ceremony between NCAC and ELBBL | 21 Feb 2024

On February 21, 2024, National Commercial Arbitration Centre (NCAC) and ELBBL-English Language Based Bachelor of Law Program (ELBBL) of Royal University of Law and Economics hosted a MoU Signing Ceremony presided by Mr. SAN Kiri, President of NCAC, and Mrs. Margaret Ryan, Director of ELBBL/ELBML with the participation from both institutions.



# 5. NCAC GOALS

NCAC's version is to enable business environment which contributes to equitable economic growth and prosperous society in Cambodia.

NCAC has its mission to become a leading neutral, non-bias, time and cost-saving commercial arbitration body in Cambodia. NCAC Goals, includes:

- Gain greater trusted from public and private sectors locally and internationally,
- Collaborate with all relevant stakeholders to make Cambodia an arbitration friendly jurisdiction,
- Increase visibility of the NCAC and Cambodia internationally to expand broader operation,
- Develop necessary infrastructure for sustainable operation and development.

NCAC *Arbitral Award, enforceable beyond National Boundary!*